**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧៧១...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែប្រែនិងការដំឡើងប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៣៩៨ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីឋានន្តរស័ក្តិនិងថ្នាក់សម្រាប់ចៅក្រមនិងព្រះរាជអាជ្ញា
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៦ ស្តីពីប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា១.-**

ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា ត្រូវបានកែប្រែនិងដំឡើងដូចខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់(រៀល) |
|---|---|---|
| ១ | - ប្រធានតុលាការកំពូល<br>- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល | ១០ ០០០ ០០០ |



ឃ

| ល.រ | បរិយាយ | ប្រាក់បំណាច់(រៀល) |
|---|---|---|
| ២ | - អនុប្រធានតុលាការកំពូល<br>- ប្រធានសភានៃតុលាការកំពូល<br>- អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល<br>- ប្រធានសាលាឧទ្ធរណ៍<br>- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | ៤ ៨០០ ០០០ |
| ៣ | - ចៅក្រមតុលាការកំពូល<br>- ព្រះរាជអាជ្ញាអមតុលាការកំពូល<br>- អនុប្រធានសាលាឧទ្ធរណ៍<br>- ប្រធានសភានៃសាលាឧទ្ធរណ៍<br>- អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ | ៤ ៣០០ ០០០ |
| ៤ | - ចៅក្រមសាលាឧទ្ធរណ៍<br>- ប្រធានសាលាដំបូង<br>- ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍<br>- ព្រះរាជអាជ្ញាអមសាលាដំបូង<br>- ព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌ | ៣ ៨០០ ០០០ |
| ៥ | - អនុប្រធានសាលាដំបូង<br>- ប្រធានតុលាការជំនាញនៃសាលាដំបូង<br>- ព្រះរាជអាជ្ញារងអមសាលាដំបូង | ៣ ៥០០ ០០០ |
| ៦ | - ចៅក្រមសាលាដំបូង | ៣ ៣០០ ០០០ |
| ៧ | - ចៅក្រមកម្មសិក្សា<br>- ព្រះរាជអាជ្ញារងកម្មសិក្សា | ២ ០០០ ០០០ |

**មាត្រា២ .-**

ប្រាក់បំណាច់ខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ តទៅ។

**មាត្រា៣ ..**

ការផ្ដល់ជូនប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា ដូចមានចែងក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវបានអនុញ្ញាតអនុវត្តចំពោះករណីដូចខាងក្រោម៖

១- ចំពោះប្រាក់បំណាច់ព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌ ដូចមានចែងក្នុងលេខរៀងទី៤ ត្រែទី៤នៃមាត្រា១ខាងលើ ត្រូវអនុវត្តចំពោះតែព្រះរាជអាជ្ញាដែលត្រូវបានចាត់តាំងឱ្យទៅបម្រើការងារនៅអគ្គាធិការដ្ឋានកិច្ចការតុលាការ អគ្គនាយកដ្ឋានកិច្ចការអយ្យការនិងព្រហ្មទណ្ឌ និងអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ប៉ុណ្ណោះ។ ចំពោះព្រះរាជអាជ្ញាដែលបម្រើការងារនៅអង្គភាពផ្សេងរបស់ក្រសួងយុត្តិធម៌ ត្រូវទទួលប្រាក់បំណាច់ដូចមន្ត្រីរាជការស៊ីវិលដទៃទៀត។

២- ចំពោះចៅក្រមនិងព្រះរាជអាជ្ញាដែលត្រូវទទួលទណ្ឌកម្មវិន័យផ្លាស់ដោយបង្ខំឱ្យមកបម្រើការងារនៅក្រសួងយុត្តិធម៌ ត្រូវទទួលប្រាក់បំណាច់ដូចពេលដែលសាមីខ្លួនបម្រើការងារនៅសាលាជម្រះក្ដីឬអង្គការអយ្យការអមសាលាជម្រះក្ដី។

**មាត្រា៤ ..**

ប្រាក់បំណាច់ឈ្នួលផ្ទះ គឺជាចំណែកមួយនៃប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា ដែលត្រូវផ្ដល់ជូនចៅក្រមនិងព្រះរាជអាជ្ញានៅពេលត្រូវផ្លាស់ប្ដូរទីតាំងការងារ ឱ្យទៅបម្រើការងារនៅតាមសាលាជម្រះក្ដីឬអង្គការអយ្យការអមសាលាជម្រះក្ដី ហើយគ្មានអគាររបស់រដ្ឋឬផ្ទះសម្រាប់ស្នាក់នៅ។

ប្រាក់បំណាច់ឈ្នួលផ្ទះ ត្រូវផ្ដល់ជូនចៅក្រមនិងព្រះរាជអាជ្ញាចំនួន ៤០០ ០០០ (បួនសែន)រៀលម្នាក់ក្នុង១(មួយ)ខែ ក្នុងតារាងទូទាត់បៀវត្សដែលគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ។ ប្រាក់បំណាច់ឈ្នួលផ្ទះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ តទៅ។

**មាត្រា៥ ..**

ចៅក្រមនិងព្រះរាជអាជ្ញាដែលត្រូវផ្លាស់ប្ដូរទីតាំងការងារ ឱ្យទៅបម្រើការងារនៅតាមសាលាជម្រះក្ដីឬអង្គការអយ្យការអមសាលាជម្រះក្ដី ហើយគ្មានអគាររបស់រដ្ឋឬផ្ទះសម្រាប់ស្នាក់នៅ ត្រូវរៀបចំស្វ័យប្រកាសអះអាងពីតម្រូវការប្រាក់បំណាច់ឈ្នួលផ្ទះ ជូនអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីរៀបចំសំណើជូនក្រសួងយុត្តិធម៌ចេញប្រកាសស្ដីពីការទទួលស្គាល់ចៅក្រមនិងព្រះរាជអាជ្ញា ដែលត្រូវទទួលប្រាក់បំណាច់ឈ្នួលផ្ទះ។ គំរូស្វ័យប្រកាសអះអាងពីតម្រូវការប្រាក់បំណាច់ឈ្នួលផ្ទះ មានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ ..**

ប្រាក់ឧបត្ថម្ភសម្រាប់សវនាការជំនុំជម្រះក្ដីរបស់តុលាការ ត្រូវបន្តអនុវត្តតាមប្រកាសរួមលេខ ៤៩៤ សហវ ប្រក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីប្រាក់ឧបត្ថម្ភសម្រាប់សវនាការជំនុំជម្រះក្ដីរបស់តុលាការ រហូតដល់មានការសម្រេចជាថ្មី។

**មាត្រា៧.-**

ការកែប្រែនិងការដំឡើងប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា ឬ ប្រាក់ឧបត្ថម្ភសម្រាប់សវនាការជំនុំជម្រះក្តីរបស់តុលាការ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| **ឧបនាយករដ្ឋមន្ត្រី**<br>**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** | **រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** |
|---|---|---|
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **អង្គ វង្សវឌ្ឍានា** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩
ស្ដីពីការកែប្រែនិងការដំឡើងប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ស្វ័យប្រកាស
## អះអាងពីតម្រូវការប្រាក់បំណាច់ឈ្នួលផ្ទះ

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | ទីកន្លែងបំពេញការងារ | បរិយាយមុខតំណែង | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើមផ្លាស់ប្ដូរទីតាំងការងារនិងបញ្ចប់ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | ចាប់ផ្ដើមការងារ | បញ្ចប់ការងារ | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

### សេចក្ដីបញ្ជាក់

ខ្ញុំបាទ/នាងខ្ញុំ សូមបញ្ជាក់ថា ការបំពេញស្វ័យប្រកាសនេះ ដើម្បីទទួលបានប្រាក់បំណាច់ឈ្នួលផ្ទះ ព្រោះការផ្លាស់ប្ដូរទីតាំងការងារមកទីនេះ ខ្ញុំបាទ/នាងខ្ញុំ គ្មានផ្ទះស្នាក់នៅយ៉ាងពិតប្រាកដ ម្យ៉ាងទៀតអគាររដ្ឋសម្រាប់ស្នាក់នៅក៏គ្មានដែរ។ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើការអះអាងខាងលើនេះ មិនពិតប្រាកដ។

ថ្ងៃ..................... ខែ......... ឆ្នាំ.. ................. ព.ស..............
ធ្វើនៅ...................... ថ្ងៃទី........ ខែ.......... ឆ្នាំ...................

**ហត្ថលេខានិងឈ្មោះ**